## ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# សេចក្តីប្រកាសព័ត៌មាន

កន្លងមកនៅតាមបណ្តាញព័ត៌មានសង្គម ពិសេសប្រព័ន្ធព័ត៌មានហ្វេសបុក បានបង្ហាញពីវត្តមាននៃអង្ករប្លាស្ទិចនៅលើទីផ្សារដែលនាំឱ្យប៉ះពាល់ដល់តម្លៃអង្ករកម្ពុជាទាំងនៅលើទីផ្សារជាតិ និងអន្តរជាតិ។ ករណីនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសហការជាមួយសហព័ន្ធស្រូវអង្ករកម្ពុជាដោយបានបញ្ជូនសំណាកគំរូអង្ករដែលសង្ស័យថា ជាអង្ករប្លាស្ទិចមកវិភាគនៅមន្ទីរពិសោធន៍ជាតិកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មដើម្បីវិភាគ និងកំណត់អត្តសញ្ញាណអង្ករនោះ។ មន្ទីរពិសោធន៍ជាតិកសិកម្មបានធ្វើការវិភាគសំណាកគំរូអង្ករតាមបច្ចេកទេសដូចខាងក្រោម៖

ក. ការវិភាគលក្ខណៈរូប តាមរយៈការវាស់ដង់ស៊ីតេអង្ករ និងការវាស់ដង់ស៊ីតេម្សៅអង្ករ។

ខ. ការវិភាគលក្ខណៈគីមី ដើម្បីស្រាវជ្រាវរកកម្រិតប្រូតេអ៊ីនក្នុងអង្ករ។

គ. ការរំលាយអង្ករ ដោយប្រើប្រាស់អាស៊ីតខ្លាំង (Nitric Digestion)។

យោងតាមលទ្ធផលពិសោធន៍ខាងលើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជម្រាបជូនជាព័ត៌មានថា គំរូអង្ករដែលបានប្រគល់ឱ្យដោយសហព័ន្ធស្រូវអង្ករកម្ពុជាពុំមានវត្តមានប្លាស្ទិចនៅក្នុងអង្ករនោះទេឡើយ។ ដូចនេះ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។ ដោយឡែក ក្នុងករណីមានការសង្ស័យពាក់ព័ន្ធនឹងវត្តមានអង្ករប្លាស្ទិចនៅទីកន្លែងណានោះ សូមមេត្តាផ្តល់ព័ត៌មានដល់ក្រុមការងារ/មន្ត្រីបង្គោល (ការផ្ទុះរាលដាលជំងឺកើតថ្មីនៃការពុលចំណីអាហារ) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសមត្ថកិច្ចជំនាញដែលនៅជិតបំផុត ដើម្បីមានវិធានការទាន់ពេលវេលា ឬតាមរយៈប្រព័ន្ធទូរស័ព្ទៈ (៨៥៥)២៣ ២១៣ ១០៧, (៨៥៥)៧៨ ៦៧៣ ២២៥, (៨៥៥)១២ ២២២ ២៦១។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរដែនដីព្រមទាំងសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ អាជីវករ និងសាធារណជនទាំងអស់ នឹងចូលរួមតាមសេចក្តីប្រកាសព័ត៌មាននេះ ក្នុងស្មារតីសហប្រតិបត្តិការខ្ពស់។

រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320